**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានស្ថិតិ និងពត៌មាន ចំណុះអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងពាណិជ្ជកម្ម

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ស ំ រេ ច**

**មាត្រា ១ ._**

ត្រូវបានបង្កើត នាយកដ្ឋានស្ថិតិ និងពត៌មាន ចំណុះអគ្គនាយកដ្ឋានបច្ចេកទេស នៃ ក្រសួងពាណិជ្ជកម្ម ។

www.pheakdeylaw.com

**មាត្រា ២ ._**

នាយកដ្ឋានស្ថិតិ និងពត៌មាន មានភារកិច្ច ដូចតទៅ :

- ស្រាវជ្រាវ និងធ្វើស្ថិតិពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការលើវិស័យស្ថិតិពាណិជ្ជកម្ម ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- សិក្សា និង សហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំ អង្កេត ប្រមូល ចងក្រង និង វិភាគពត៌មានស្ថិតិពាណិជ្ជកម្ម
- ចងក្រង និង ណែនាំអនុវត្តដោយឯកភាព តាមចំណាត់ថ្នាក់ពត៌មានស្ថិតិពាណិជ្ជកម្ម និងបណ្តាតារាងគំរូ
- ផ្សព្វផ្សាយទិន្នន័យស្ថិតិពាណិជ្ជកម្ម ស្តីពីស្ថានភាពនៃការវិវត្តន៍ក្នុងផ្នែកពាណិជ្ជកម្ម ក្នុង និងក្រៅប្រទេស
- ស្រាវជ្រាវ វិភាគ ផ្សព្វផ្សាយការប្រែប្រួលថ្លៃទំនិញចរាចរក្នុងប្រទេស និងត្រួតពិនិត្យតាមដានទិន្នាការសន្ទស្សន៍ថ្លៃរបស់បណ្តាប្រទេសនានា
- សិក្សា ស្រាវជ្រាវ ប្រមូល និងវិភាគពត៌មានតាមលំដាប់ដើម្បីបង្កើតតារាង នៃការប្រែប្រួលថ្លៃ និងការប្រែប្រួលគុណភាព
- ប្រមូលយកពត៌មានអំពីថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម តាមកាលកំណត់ និងចងក្រងការប្រែប្រួលថ្លៃទំនិញប្រើប្រាស់ និងសេវាប្រចាំខែ ត្រីមាស ៩ខែ និងប្រចាំឆ្នាំ
- ធ្វើគំរោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញស្ថិតិពាណិជ្ជកម្ម និងពត៌មានពាណិជ្ជកម្មពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋានតាមតំរូវការការងារ
- ទទួលបន្ទុកជា មជ្ឈមណ្ឌលពត៌មានពាណិជ្ជកម្ម របស់ក្រសួង
- គ្រប់គ្រង និងអភិវឌ្ឍន៍ពត៌មាន ប្រព័ន្ធទិន្នន័យសេដ្ឋកិច្ច ពាណិជ្ជកម្ម
- គ្រប់គ្រង និងអភិវឌ្ឍន៍បច្ចេកទេសពត៌មានវិទ្យា ។

**មាត្រា ៣ ._**

នាយកដ្ឋានស្ថិតិ និងពត៌មាន ដឹកនាំ ដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ ។



www.pheakdeylaw.com

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ - កាលប្បវត្តិ



www.pheakdeylaw.com